**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អអក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ០២៤/សណ/១៧ អអក

ភ្នំពេញ, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១៧

## សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
## ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណលើកទី៤ របស់ក្រុមហ៊ុន ខេ អ វ៉ាយ ត្រេឌីង សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកបាណន់ និង ស្រុកសង្កែ ខេត្តបាត់ដំបង

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយស សូមជម្រាបជូនសាធារណជន នៅផ្នែកខ្លះនៃស្រុកបាណន់ និងស្រុកសង្កែ ខេត្តបាត់ដំបង ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជា គ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណលើកទី៤ របស់ក្រុមហ៊ុន ខេ អ វ៉ាយ ត្រេឌីង ដើម្បីធ្វើការកែសម្រួលម្ចាស់ភាគហ៊ុន នៃអ្នកកាន់អាជ្ញាបណ្ណ តាមខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណ ដូចមានជូនភ្ជាប់មកជាមួយនេះ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ពន្ធ័ និងសាធារណជន មានសិទ្ធិពិនិត្យផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា លើខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណដែលគ្រោង នឹងផ្តល់នេះ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណនៅ.................. ..........................................................................................................សម្រាប់សាធារណជនពិនិត្យ។

អាស្រ័យហេតុនេះ សូមសាធារណជននៅផ្នែកខ្លះនៃស្រុកបាណន់ និងស្រុកសង្កែ ខេត្តបាត់ដំបង ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណ ឲ្យក្រុមហ៊ុន ខេ អ វ៉ាយ ត្រេឌីង អញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា ចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា "អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណាដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ" ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,

ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

EAC

# អាជ្ញាធរអគ្គិសនីកម្ពុជា

**ELECTRICITY AUTHORITY OF CAMBODIA**

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

**ELECTRICITY LAW OF THE KINGDOM OF CAMBODIA**

# សេចក្តីសម្រេចកែសម្រួលលើកទី៤
# លើឯកសារអាជ្ញាបណ្ណលេខ ២៤៤ ឯអ ចុះថ្ងៃទី04 ខែសីហា ឆ្នាំ២០០៩ សម្រាប់ក្រុមហ៊ុន ខេ អ វ៉ាយ ត្រេឌីង សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកបាណន់ និងស្រុកសង្កែ ខេត្តបាត់ដំបង

## សម្រាប់ការកែសម្រួលសមាសភាពភាគហ៊ុននៃអ្នកកាន់អាជ្ញាបណ្ណ

## DECISION ON THE FOURTH REVISION

TO THE LICENSE DOCUMENT No. 244 LD DATED AUGUST 04, 2009
FOR K.R.Y TRADING CO.,LTD. FOR PROVIDING ELECTRIC POWER
SERVICE AT SOME PART OF BANON AND SANGKER DISTRICTS,
BATTAMBANG PROVINCE

## FOR CHANGING THE SHAREHOLDER OF LICENSEE

ថ្ងៃទី ខែ ឆ្នាំ២០១៧

, 2017